00287662

C22/5/28

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ១៧) |
| ដាក់ទៅ: | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់: | ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៩ |
| ភាគីអ្នកដាក់: | សហមេធាវីរបស់លោក **អៀង សារី** |
| ភាសាដើម: | អង់គ្លេស ជាភាសាដើម |
| ប្រភេទឯកសារ: | សាធារណៈ |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 12 / 03 / 2009
ម៉ោង (Time/Heure): 09 : 25
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សំណើ*ជាបន្ទាន់*របស់លោក អៀង សារី សុំឲ្យលោកវេជ្ជបណ្ឌិត PAULUS FALKE ផ្តល់ភស្តុតាងកោសលវិច្ច័យ នៅក្នុងអំឡុងពេលសវនាការផ្ទាល់មាត់ ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩**

**និង**

**សំណើសុំកាលបរិច្ឆេទដាក់ឯកសារជាបន្ទាន់**

---

**អ្នកដាក់ឯកសារ:**

**សហមេធាវី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

ឯកសារដើមត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ (Certified Date/Date de certification): 12 / MAR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

**អ្នកទទួលឯកសារ:**

**ចៅក្រមអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គីមសាន

លោក ន័យ ធុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**សហព្រះរាជអាជ្ញា:**

លោកស្រី ជាលាង

លោក Robert PETIT

តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារ") ដោយអនុលោមតាមវិធានផ្ទៃក្នុង៣១(១) និង៣១(១០) តទៅនេះ លោក **អៀង សារី** សូមសំណូមពរដោយក្តីគោរពមេត្តាចាត់តាំងលោកវេជ្ជបណ្ឌិត Paulus Falke ជាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ និងកោះអញ្ជើញឱ្យផ្តល់ភស្តុតាងនៅក្នុងអំឡុងពេលសវនាការដេញដោលផ្ទាល់មាត់ នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩ ខាងមុខនេះ។

## I. សេចក្តីផ្តើម

1. មេធាវីការពារបានស្នើសុំឱ្យលោកវេជ្ជបណ្ឌិត Falke ដែលជាមន្ត្រីសុខាភិបាលរបស់អង្គការសហប្រជាជាតិប្រចាំនៅមន្ទីរឃុំឃាំងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី (ICTY UNDU) ពិនិត្យមើលរបាយការណ៍វេជ្ជសាស្ត្រនានារបស់លោក **អៀង សារី** ឡើងវិញ។[1]

2. លោកវេជ្ជបណ្ឌិត Falke បានពិនិត្យរបាយការណ៍វេជ្ជសាស្ត្រទាំងអស់នេះរួចហើយ ព្រមទាំងបានរៀបចំរបាយការណ៍សង្ខេបមួយ ដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងរួចទៅហើយ[2] ដោយអនុលោមតាមសំណើសុំរបស់មេធាវីការពារ ដែលក្នុងសំណើនោះ មេធាវីការពារក៏បានស្នើសុំឱ្យ

---

[1] រឿងក្តីរបស់ អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, របាយការណ៍វេជ្ជសាស្ត្ររបស់ជំនាញ ចុះថ្ងៃទី ៥ មីនា ២០០៨ ។ រឿងក្តីរបស់ អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស របាយការណ៍វេជ្ជសាស្ត្ររបស់ជំនាញ ចុះថ្ងៃទី៩ តុលា ២០០៨ ។ រឿងក្តីរបស់ អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, របាយការណ៍កោសល្យវិច្ច័យផ្នែកវេជ្ជសាស្ត្ររបស់ជំនាញ ចុះថ្ងៃទី១៤ ឧសភា ២០០៨ ។ រឿងក្តីរបស់ អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស របាយការណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យកាល់ម៉ែត ចុះថ្ងៃទី២៨ មករា ២០០៨ ។ របាយការណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យកាល់ម៉ែត ចុះថ្ងៃទី៩ កុម្ភៈ ២០០៨។ របាយការណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យកាល់ម៉ែត ចុះថ្ងៃទី៧ មីនា ២០០៨ ។ របាយការណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យកាល់ម៉ែត ចុះថ្ងៃទី២៤ ធ្នូ ២០០៨ ។ រឿងក្តីរបស់ អៀង សារី សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស របាយការណ៍វេជ្ជសាស្ត្ររបស់មន្ទីរពេទ្យកាល់ម៉ែត ដែលចេញដោយវេជ្ជបណ្ឌិត នេត្រ ផល្លា ចុះថ្ងៃទី១១ ធ្នូ ឆ្នាំ២០០៨ ។

[2] រឿងក្តីរបស់ អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សេចក្តីណែនាំដល់ភាគីទាំងអស់ពាក់ព័ន្ធនឹងសំណើរបស់ អៀង សារី ស្នើសុំឱ្យដាក់បន្ថែមរបាយការណ៍វេជ្ជសាស្ត្ររបស់លោកវេជ្ជបណ្ឌិត Paulus Falke ទៅក្នុងសំណុំរឿង និងបានស្នើសុំការអនុញ្ញាតឱ្យលោកវេជ្ជបណ្ឌិត Paulus Falke ផ្តល់ភស្តុតាង តាមរយៈបណ្តាញវីដេអូនៅក្នុងសវនាការ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩, នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ ២ ។

លោកវេជ្ជបណ្ឌិត Falke ផ្តល់ភស្តុតាងនៅក្នុងសវនាការដេញដោលផ្ទាល់មាត់ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩[3] ។

3. លោកវេជ្ជបណ្ឌិត Falke បានបង្ហាញជូនមេធាវីការពារនូវឆន្ទៈ និងលទ្ធភាពពេលវេលារបស់គាត់ ក្នុងការផ្តល់ភស្តុតាងផ្ទាល់មាត់តាមរយៈបណ្តាញវីដេអូ ស្តីពី ខ្លឹមសារនៃរបាយការណ៍របស់គាត់ ប្រសិនបើ អង្គបុរេជំនុំជម្រះផ្តល់ការជូនដំណឹងបានទាន់ពេលវេលា ដើម្បីឱ្យគាត់រៀបចំចាត់ចែងពេលវេលាដ៏មមាញឹករបស់គាត់[4]។

4. អង្គបុរេជំនុំជម្រះបានច្រានចោលសំណើរបស់មេធាវីការពារ ស្នើសុំឱ្យលោកវេជ្ជបណ្ឌិត Falke ផ្តល់ភស្តុតាង ដោយការយល់ឃើញថា សំណើនោះគឺ "ដើម្បីស្តាប់លោកវេជ្ជបណ្ឌិត Falke ក្នុងនាមជាសាក្សី គឺមិនមែនសំណើសុំចាត់តាំងគាត់ជាជំនាញនោះទេ។ ភស្តុតាងដែលគាត់អាចផ្តល់ជូនគឺមានលក្ខណៈប្រយោល[5]"។

5. ក្នុងពេលនេះ មេធាវីការពារស្នើសុំឱ្យតែងតាំងលោកវេជ្ជបណ្ឌិត Falke ជាអ្នកជំនាញវេជ្ជសាស្ត្រ និងកោះអញ្ជើញគាត់ឱ្យផ្តល់ភស្តុតាង ក្នុងនាមជាអ្នកជំនាញមួយរូប នៅក្នុងអំឡុងពេលសវនាការដេញដោលផ្ទាល់មាត់ ស្តីពី បណ្តឹងឧទ្ធរណ៍របស់លោក **អៀង សារី** ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន ដែលមានកាលបរិច្ឆេទ នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩ ខាងមុខនេះ។

## II. ច្បាប់ដែលនៅជាធរមាន

---

[3] រឿងក្តីរបស់ អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ១៧) សំណើរបស់ អៀង សារី ស្នើសុំឱ្យដាក់បន្ថែមរបាយការណ៍វេជ្ជសាស្ត្ររបស់លោកវេជ្ជបណ្ឌិត Paulus Falke ទៅក្នុងសំណុំរឿង និងសុំការអនុញ្ញាតឱ្យលោកវេជ្ជបណ្ឌិត Paulus Falke ផ្តល់ភស្តុតាង តាមរយៈបណ្តាញវីដេអូ នៅក្នុងសវនាការទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ចុះថ្ងៃទី ២០ កុម្ភៈ ២០០៩ (សំណើសុំលោក Falke ជាលើកទីមួយ)។

[4] មេធាវីការពារក៏បានពិគ្រោះយោបល់ជាមួយផ្នែកគ្រប់គ្រងតុលាការផងដែរ និង បានជូនដំណឹងរួចមកហើយថា ប្រសិនបើអ្នកជំនាញត្រូវបានអញ្ជើញឱ្យផ្តល់ភស្តុតាងតាមរយៈបណ្តាញវីដេអូ នោះការរៀបចំចាត់ចែងសន្តិសុខ និងបច្ចេកទេស អាចចំណាយពេលវេលាលើសពី ២ ថ្ងៃ ដើម្បីរៀបចំ និងសាកល្បង។

[5] រឿងក្តីរបស់ អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចផ្ទាល់មាត់ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពី សំណើនានាដែលបានដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងអំឡុងពេលសវនាការផ្ទាល់មាត់ នៅថ្ងៃតែមួយ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ ២ ។

6. អនុលោមតាមវិធានផ្ទៃក្នុង ៣១(១) អង្គបុរេជំនុំជម្រះអាច "ស្វែងរកជំនួយជាមតិយោបល់ពីអ្នកជំនាញ អំពីបញ្ហាដែលយល់ឃើញថា មានសារៈសំខាន់ចាំបាច់ដល់ [...] កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក"។ ភាគីមួយអាចស្នើសុំឱ្យអង្គបុរេជំនុំជម្រះ "តែងតាំងអ្នកជំនាញបន្ថែមទៀត ដើម្បីធ្វើការពិនិត្យជាថ្មី ឬពិនិត្យឡើងវិញនូវបញ្ហាដែលជាកម្មវត្ថុនៃរបាយការណ៍របស់អ្នកជំនាញមួយរួចទៅហើយនោះ។ សំណើសុំនេះត្រូវតែធ្វើជាលាយលក្ខអក្សរ និងត្រូវផ្តល់ហេតុផល"[6]។

## III. ឧទ្ធរណ៍ករណ៍

7. អង្គបុរេជំនុំជម្រះបានទទួលយកភាពចាំបាច់ ក្នុងការកោះអញ្ជើញអ្នកជំនាញវេជ្ជសាស្ត្រដើម្បីសាកសួរផ្ទាល់មាត់ នៅក្នុងសវនាការស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន[7]។ អង្គបុរេជំនុំជម្រះក៏បានអនុញ្ញាតឱ្យមានការពិភាក្សាយ៉ាងយូរ ទៅលើរបាយការណ៍វេជ្ជសាស្ត្ររបស់លោក **អៀង សារី** ក្នុងអំឡុងពេលសវនាការផ្ទាល់មាត់ ស្តីពី ការឃុំខ្លួនបណ្តោះអាសន្ន ដែលបាន ធ្វើឡើងកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨[8] កន្លងទៅនេះ។ ហេតុដូច្នេះ មតិយោបល់របស់អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ គឺពិតជាមានសារៈសំខាន់យ៉ាងជាក់ច្បាស់ និងដោយផ្ទាល់ ពាក់ព័ន្ធនឹងសវនាការដេញដោលផ្ទាល់មាត់ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបន្តថេរៈវេលាឃុំខ្លួនបណ្តោះអាសន្នមែន។

8. ការកោះអញ្ជើញលោកវេជ្ជបណ្ឌិត Falke ឱ្យមកផ្តល់ភស្តុតាងនៅក្នុងសវនាការនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩ នេះ គឺពិតជាមានសារៈសំខាន់បំផុត។ លោកវេជ្ជបណ្ឌិត Falke ជាមន្ត្រីវេជ្ជសាស្ត្រទទួលខុសត្រូវលើការថែទាំវេជ្ជសាស្ត្រ និងស្ថានភាពសុខភាពរបស់ជនជាប់ឃុំឃាំង នៅក្នុងមន្ទីរឃុំឃាំងរបស់អង្គការសហប្រជាជាតិ (UNDU) នៅមន្ទីរឃុំឃាំងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

---

[6] វិធានផ្ទៃក្នុង ៣១(១) (គូសបញ្ជាក់បន្ថែម)។

[7] នៅក្នុងសវនាការដេញដោលផ្ទាល់មាត់ ស្តីពី ការប្តឹងឧទ្ធរណ៍លើកទីដំបូងរបស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កាលពីខែកក្កដា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានកោះអញ្ជើញវេជ្ជបណ្ឌិត នេត្រ ផល្លា ប្រធានមន្ទីរសុខាភិបាលរបស់ អ.វ.ត.ក ដើម្បីឱ្យមេធាវីការពារសាកសួរពីបញ្ហាសុខភាពរបស់លោក អៀង សារី។ សូមមើលរឿងក្តីរបស់ អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អជប០៣), កំណត់ហេតុសវនាការ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៨ ទំព័រទី ៨-១០។

[8] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អជប០៣), កំណត់ហេតុសវនាការ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៨ ទំព័រទី ៣-៥។

សម្រាប់អតីតយុហ្គោស្លាវី ក្នុងរយៈពេលជាងដប់ឆ្នាំកន្លងមកនេះ[9] ហើយក៏បានទទួលមើលខុសត្រូវជាប់ឃុំឃាំងពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ចាប់តាំងពីការបង្កើតស្ថាប័ននោះក្នុងឆ្នាំ២០០២ មកម្ល៉េះ។ គាត់មានលក្ខណៈសម្បត្តិប្លែកដាច់គេ ក្នុងការជួយដល់អង្គបុរេជំនុំជម្រះឲ្យយល់ពីរបាយការណ៍វេជ្ជសាស្ត្រផ្សេងៗមកលើរូបលោក **អៀង សារី** យល់ដឹងពីបទដ្ឋានអប្បបរិមានានានៃការព្យាបាលវេជ្ជសាស្ត្រផ្សេងៗ និងការធ្វើតេស្តដែលមនុស្សមានសុខភាព និងអាយុដូចលោក **អៀង សារី** អាចត្រូវធ្វើឡើង ហើយនឹងមានសិទ្ធិទទួលបានបែបនេះប្រសិនបើត្រូវបានគេឃុំខ្លួននៅ UNDU ក្នុងទីក្រុងឡាអេ និងផលប៉ះពាល់នៃការឃុំខ្លួនដែលអូសបន្លាយមកលើសុខភាពរបស់បុគ្គលជាប់ឃុំឃាំង ។

9. ការដែលលោកវេជ្ជបណ្ឌិត Falke មិនបានពិនិត្យមើលលោក **អៀង សារី** ដោយផ្ទាល់ ប៉ុន្តែ គ្រាន់តែបានពិនិត្យឡើងវិញ និងបានវិភាគលើរបាយការណ៍វេជ្ជសាស្ត្រ ដែលធ្វើឡើងដោយវេជ្ជបណ្ឌិតផ្សេងៗដែលបានពិនិត្យ និងព្យាបាលលោក **អៀង សារី** នោះ មិនបានធ្វើឲ្យខូចដល់តម្លៃនៃភស្តុតាងរបស់គាត់នោះទេ។ ពុំមានលក្ខខណ្ឌតម្រូវឲ្យអ្នកជំនាញត្រូវផ្តល់ភស្តុតាងដោយផ្ទាល់ ដែលនេះគឺផ្ទុយគ្នាចំពោះសាក្សី។ ការពិត លោកវេជ្ជបណ្ឌិត Falke អាចនឹងផ្តល់ភស្តុតាងដល់ អង្គបុរេជំនុំជម្រះ អំពីនីតិវិធីដែលបានអនុវត្តដោយវេជ្ជបណ្ឌិតរបស់ អ.វ.ត.ក និងអ្នកជំនាញនានា ដែលតែងតាំងដោយ ក.ស.ច.ស និងផ្តល់ភស្តុតាងថា តើវេជ្ជបណ្ឌិត និងអ្នកជំនាញទាំងនេះប្រើប្រាស់វិធានការដល់កម្រិតបទដ្ឋានអន្តរជាតិ ដែរឬទេ ជាជាងផ្តល់ភស្តុតាងថា តើលទ្ធផលនៃការពិនិត្យ និងការធ្វើតេស្តរបស់អ្នកទាំងនោះត្រឹមត្រូវដែរឬយ៉ាងណានោះទេ។

## IV. សំណូមពរ

**យោងលើ**មូលហេតុដូចបានលើកឡើងនៅទីនេះ មេធាវីការពារសំណូមពរដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះមេត្តា៖

ក. **អនុញ្ញាត**ឲ្យលោកវេជ្ជបណ្ឌិត Falke ផ្តល់ភស្តុតាងផ្តល់ភស្តុតាងក្នុងនាមជាអ្នកជំនាញនៅក្នុងអំឡុងពេលសវនាការផ្ទាល់មាត់ នាថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩ ខាងមុខនេះ និង

---

[9] សូមមើលប្រវត្តិរូបរបស់លោកវេជ្ជបណ្ឌិត Falke ដែលបានភ្ជាប់ជាមួយឧបសម្ព័ន្ធ ក។

00287667

C22/5/28



ខ. **បង្គាប់ដល់ភាគីទាំងអស់នៅក្នុងសំណុំរឿងលេខ ០០២ ឆ្លើយតបនឹងសំណើនេះត្រឹមថ្ងៃទី១៧** ខែមីនា ឆ្នាំ២០០៩ ដើម្បីបង្កលក្ខណៈងាយស្រួលឲ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេចសេចក្តីទៅលើសំណើនេះបានទាន់ពេលវេលា ដើម្បីឲ្យមេធាវីការពារ និងផ្នែកគ្រប់គ្រងតុលាការធ្វើការរៀបចំចាត់ចែងដែលចាំបាច់នានាឲ្យលោកវេជ្ជបណ្ឌិត Falke ផ្តល់ភស្តុតាងតាមរយៈបណ្តាញវីដេអូ។

សូមអង្គបុរេជំនុំជម្រះទទួលយកសំណើសុំនេះដោយក្តីគោរព។

**ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១២ ខែមីនា ឆ្នាំ ២០០៩**

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**